# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណីវីរ ជា ហៅ សែន I06781
## ជួបសម្ភាសន៍ផ្ទាល់ជាមួយ វីរ ជា អាយុ៥១ឆ្នាំ ជាម្ចាស់ប្រវត្តិរូប
## នៅភូមិវាល ឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម
## ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣
## សម្ភាសដោយៈ សុខ វណ្ណៈ
## សរុបៈ ១៨ទំព័រ

វណ្ណៈ៖ អត់ទោសពូ ពូឈ្មោះអីដែរ?

សែនៈ សព្វថ្ងៃខ្ញុំឈ្មោះ វីរ ជា ។

វណ្ណៈ៖ វីរ ជា ឈ្មោះអ៊ី...ហៅអី?

សែនៈ ឈ្មោះ សែន ។

វណ្ណៈ៖ សែន ។ ពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

សែនៈ ៥១ ។

វណ្ណៈ៖ ៥១ហៃគ្រួសារពូឈ្មោះអីដែរ.

សែនៈ ប្រាក់ សំអាត ។

វណ្ណៈ៖ ប្រាក់ សំអាត គាត់អាយុប៉ុន្មានហើយ?

សែនៈ ៤៧ ។

វណ្ណៈ៖ បាទ! ពូមានបងប្អូនទាំងអស់ប៉ុន្មាននាក់?

សែនៈ បងប្អូនខ្ញុំទាំងអស់៣នាក់ ។

វណ្ណៈ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានហើយ?

សែនៈ ស្រី២ ប្រុស១ ។

វណ្ណៈ៖ អីចឹង ប្រុសតែពូមួយទេអីចឹង?

សែនៈ ហ្អេ មិនមែនទេ៤នាក់ណោះ ប៉ុន្តែ ប៉ុល ពត វៃចោល១បាត់ហ្អើយបងគេ ។

វណ្ណៈ៖ បាទ! ចុះឪពុកពូឈ្មោះអីដែរពូ?

សែនៈ ឈ្មោះ ទុំ ។

វណ្ណៈ បាទ! ចុះម្តាយពូ?

សែនៈ ម្តាយឈ្មោះ ជា ។

វណ្ណៈ បាទ! ចុះលោកទាំង២សព្វថ្ងៃគាត់នៅរស់ដែរ?

សែនៈ ស្លាប់អស់ ។

វណ្ណៈ គាត់ស្លាប់ជំនាន់ណា?

សែនៈ ៧៥ ។

វណ្ណៈ គាត់ស្លាប់ដោយសារអីដែរពូ?

សែនៈ អត់បាយហើម ឪពុកខ្ញុំហើមស្គួត ពុគាមគេប្រាប់ហ្នឹង ខ្ញុំនៅអី ។

វណ្ណៈ បាទ!

សែនៈ ហើយម្តាយខ្ញុំទើបលើសឈាមងាប់ ឆ្នាំអីប៉ុន្មានទេ ។

វណ្ណៈ ដាច់ហើយ?

សែនៈ បាទ! ដាច់ហើយ ។

វណ្ណៈ បាទ! ចុះអ៊ីុ រាល់ថ្ងៃពូរស់នៅក្នុងភូមិអី ឃុំអី ស្រុកអីដែរ?

សែនៈ ខ្ញុំរស់នៅក្នុងភូមិវាល សង្កាត់សំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

វណ្ណៈ បាទ! ចុះពូរាល់ថ្ងៃពូប្រកបមុខរបរអីទៅ?

សែនៈ ប្រកបមុខរបរ កាត់សក់ ធ្វើស្រែប្រាំង ។

វណ្ណៈ បាទ! ចុះពូ កាលពីតូច ពូរៀនបានថ្នាក់ណាដែរ?

សែនៈ បានតិចដែរ ។

វណ្ណៈ រៀនបានថ្នាក់ទីប៉ុន្មាន?

សែនៈ រៀនបានថ្នាក់ទី១១ ។

វណ្ណៈ ថ្នាក់ទី១១ ចុះបន្ទាប់ម៉ោពូមានបានបួស បានអីទេ?

សែនៈ អត់ទេ ។

វណ្ណៈ ចុះពូអ៊ីុ...មូលហេតុអីបានពូចេញពីទះទៅ?

សែនៈ ម៉ាជំនាន់ហ្នឹង ចេញទៅធ្វើទ័ពហ្នឹង តាមៗគ្នា ជំនាន់ហ្នឹង គេឃោសនាទៅចេះតែទៅតាមគេ ទៅណា ទៅឆ្នាំ៧២ធ្វើទ័ព ។

វណ្ណៈ អ៊ីុ កាលពូទៅហ្នឹង អីចឹងពូទៅដោយស្ម័គ្រចិត្ត ឬតាមការឃោសនា?

សែនៈ ទៅតាមស្ម័គ្រចិត្តទេ ។

វណ្ណៈ បាទ! ចុះពូចូលបដិវត្តនៅឆ្នាំណាដែរ?

សែនៈ ឆ្នាំ៧២ ។

វណ្ណៈ ៧២ពូចាំថ្ងៃ ខែទេ?

សែនៈ អត់ចាំទេ ។

វណ្ណៈ ពូចូលបដិវត្ត ពូចូលនៅកន្លែងណាពូ ពូចូលនៅភូមិអីឃុំអីពូ?

សែនៈ កាលចូលដំបូងហ្នឹង ចូលនៅភូមិកុមាររាជ ឃុំបឹងណយ ។

វណ្ណៈ ភូមិកុមាររាជ ឃុំ?

សែនៈ ភូមិកុមាររាជ ឃុំបឹងណយ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

វណ្ណៈ ចុះពូបន្ទាប់មកទៀត ពូទៅធ្វើនៅណាទៀតទៅ?

សែនៈ ចូលធ្វើទ័ពហ្នឹង?

វណ្ណៈ បាទ!

សែនៈ ចូលទៅ នៅចម្ការលើ បកពីចម្ការលើចូលម៉ោនៅអីទឹកពុះ ។

វណ្ណៈ ពូនៅចម្ការលើនៅឆ្នាំណានៅអីចម្ការលើ?

សែនៈ ភ្លេចបាត់ហើយ ។

វណ្ណៈ កាលដែលពូចូលទ័ពដំបូងហ្នឹងពូធ្វើអីខ្លះទៅ?

សែនៈ កាលដំបូង ។

វណ្ណៈ គេឲ្យពូធ្វើអីខ្លះទៅ?

សែនៈ មានធ្វើអី កាន់តែកាំភ្លើងហាត់ហ្នឹង ។

វណ្ណៈ កាន់កាំភ្លើងហាត់?

សែនៈ បាទ!

វណ្ណៈ ហាត់ហើយបានឡើងវៃនៅកន្លែងណាខ្លះទៅ?

សែនៈ មុនដំបូងវៃនៅព្រៃទទឹង នៅព្រៃឈរអី តាមផ្លូវជាតិលេខ៧នេះ ហើយនិងវៃគគីរ ។

វណ្ណៈ បាទ! វៃជាមួយទ័ពណា?

សែនៈ ទ័ព លន់ នល់ ។

វណ្ណៈ កាលដែលពូឡើងវៃហ្នឹងទាំងទ័ពខាងពូ ទាំងទ័ព លន់ នល់ហ្នឹងមានរបួសឬក៏ស្លាប់ច្រើនដែរ?

សែនៈ បាទ! ស្លាប់ច្រើន ជំនាន់ហ្នឹង បើវៃគគីវិញអាពតដេញ លន់ នល់ ហ្នឹងទម្លាក់ស្កាត់ ព័ទ្ធពីក្រោយ ខាងខ្ញុំហ្នឹងក៏ព័ទ្ធពីក្រោយ២, ៣ដាន់ទម្រាំវៃយកបាន។

វណ្ណៈ មានស្លាប់មានអីច្រើន?

សែនៈ បាទ! មានស្លាប់ច្រើន។

វណ្ណៈ កាលហ្នុងពូនៅកងពលណាពូ?

សែនៈ កងពល៣១០។

វណ្ណៈ កងពល៣១០ កាលហ្នុងប្រធានពូឈ្មោះអីដែរពូ ប្រធានកងពល?

សែនៈ ប្រធានកងពលឈ្មោះ វឿង។

វណ្ណៈ វឿង ចុះអនុ, អនុប្រធានកងពល?

សែនៈ អនុប្រធាន ភ្លេចបាត់ហើយ។

វណ្ណៈ ចុះម៉ាកងពលពូហ្នឹងមានទ័ពប៉ុន្មានរយនាក់ដែរ?

សែនៈ ម៉ាកងពលហ្នឹង ហ្អែម៉ានទេ ក្តាប់មិនបានទេ។

វណ្ណៈ ប្រហែលច្រើនដែរទេ?

សែនៈ បាទ! ប្រហែលជា១០០០០នាក់។

វណ្ណៈ ប្រហែល១០០០០នាក់?

សែនៈ បាទ!

វណ្ណៈ កងពលពូហ្នឹងចល័តទៅដល់ណាខ្លះទៅ?

សែនៈ វៃមួយឆ្នាំហ្នឹង វៃបេនឡារូប វៃផ្តាច់អស់ បានត្រឡប់មកវៃកំពង់ចាមណោះ អានៅដេញទាហាននៅកង់ៗហ្នឹងនៅតាមខេត្តតាមអីហ្នឹងឡើងមកវៃនៅខេត្ត នៅខេត្តបានលន់ នល់ ហ្នឹងដេញត្រឡប់មកវិញ ដល់ថ្ងៃក្រោយហ្នឹង វៃក៏មិនដាច់អីក៏ចឹងបានសម្រាក សម្រាករួចបានឡើងទៅវៃទៀត វៃនៅកំពង់ចាមហ្នឹង វៃមិនដាច់ទៀតបានបកទ័ពម៉ោវៃខាងសៀមរាប។

វណ្ណៈ អូ! ពូវៃដល់សៀមរាប ទៀត?

សែនៈ បាទ! ដល់សៀមរាប ហើយដល់ពេលនេះទាហាន លន់ នល់ ហ្នឹងវៃឡើងដល់អង្គរដើរពីហ្នឹង ទៅវៃដល់អង្គរត្រឡប់មកវិញ។

វណ្ណៈ បាទ!

សែនៈ	បានបកត្រឡប់មកវិញភ្លេចឆ្នាំទៅ បានបកមកៗវៃតាមព្រែកក្តាម កំពង់ហ្លួងខាងអីត្រឡប់វិញ បកៗម៉ោបានវៃចូលភ្នំពេញវិញ ។

វណ្ណៈ	ពូវៃបានវៃចូលភ្នំពេញឆ្នាំ៧៥ហ្នឹងដែរ?

សែនៈ	បាទ!

វណ្ណៈ	ពូវៃចូលភ្នំពេញដំបូង ពូឃើញទេសភាពអីខ្លះនៅភ្នំពេញ ដូចថាឃើញសភាពអីខ្លះនៅភ្នំពេញ?

សែនៈ	បាទ! មុនដំបូងវៃដេញព្រែកក្តាម ដល់ព្រែកក្តាមហ្នឹង តែកាលហ្នឹងវៃដាច់អស់ហើយនៅតែខាងលិចហ្នឹងទៅ ។

វណ្ណៈ	បាទ!

សែនៈ	មានស្ពានអីឆ្លងទៅរួចដាក់ដើមចេកបណ្តែតទៅៗ មេបញ្ជាការថាបើវៃមិនដាច់ទេមានតែងាប់កណ្តាលទឹកហ្នឹងទេ ។

វណ្ណៈ	បាទ!

សែនៈ	ហៅសុទ្ធតាកងតូច កងធំអីអ្នកស្ម័គ្រចិត្តហ្នា ហើយបណ្តែតទៅ កាលហ្នឹងទឹកហូពីដើងត្រឡប់មកវិញដាក់បណ្តែតពីខាងកំពង់ហ្លួងមកវិញ មកដល់ព្រែកក្តាមហ្នឹងណាចេះតែកេវដៃកេវដើងទៅមកដល់ម៉ោង១អីបានគេមកជួយមកពីលិចហ្នឹងគេមកជួយ ដល់មកជួយទៅចែកផ្លូវគ្នាត្រៀមតាមកំពង់ហ្លួងបានទ័ពណោះ អ៊ីទូកឆ្លងទៅបានដាច់ណោះអស់ហើយ បានវៃនៅវៃចេតីយថ្មីវៃកំពង់ហ្លួងហ្នឹង នៅវៃទៅវៃម៉ោៗ បាន៧៥ហ្នឹងថ្ងៃ១ ខែ១ ហ្នឹងបានឆ្លង ទៅវៃបាសិទ្ធ ។

វណ្ណៈ	អីចឹងពូបានវៃទីក្រុងភ្នំពេញដែរ?

សែនៈ	បាទ! វៃបាសិទ្ធខ្សែក្រវ៉ាត់ទីក្រុងភ្នំពេញហើយវៃដាច់ភ្នំធំ ត្រពាំងព្រាយអីហើយបានវៃដល់ទះ១០០ខ្នង, អា១០០ខ្នងតូចៗហ្នឹង ។

វណ្ណៈ	បាទ!

សែនៈ	បានទៅវៃចូលដល់ទីក្រុងភ្នំពេញ ។

វណ្ណៈ	ពូវៃចូលដល់ទីក្រុងភ្នំពេញនៅថ្ងៃប៉ុន្មាន ខែ ឆ្នាំណា?

សែនៈ	៧៥ ។

វណ្ណៈ	៧៥ កាលពូចូលដល់ទីក្រុងភ្នំពេញហ្នឹងតើប្រជាជននៅក្នុងទីក្រុងភ្នំពេញហ្នឹងចាកចេញហើយឬនៅ?

សែនៈ នៅទេ ។

វណ្ណៈ នៅទេ?

សែនៈ បាទ!

វណ្ណៈ ចុះកាលហ្នឹងគេប្រាប់ប្រជាជនថាម៉េចឲ្យ?

សែនៈ ថាឲ្យប្រជាជនថយចេញមួយអាទិត្យសិន ។

វណ្ណៈ គេប្រាប់ថាឲ្យប្រជាជនថយចេញមួយអាទិត្យសិន?

សែនៈ បាទ! ថយចេញមួយអាទិត្យសិន បើមិនថយចេញប្រយ័ត្នគ្រោះថ្នាក់ ។ ហើយប្រជាជនថយអស់ទៅ ។

វណ្ណៈ ថយអស់ទៅហ្នឹ?

សែនៈ បាទ! ថយអស់ទៅ ខ្លះក៏មានឡានទៅ ខ្លះមានកង់ មានស៊ីក្លូចេះតែចេញមក ។

វណ្ណៈ បន្តបន្ទាប់ទៅ?

សែនៈ បាទ! បន្តបន្ទាប់គ្នា ។

វណ្ណៈ អីចឹងកងទ័ពពូហ្នឹងកាលចូលដល់ទីក្រុងភ្នំពេញដើរ ពូដើរតាមទីក្រុង?

សែនៈ បាទ!

វណ្ណៈ ប្រហែលរយៈពេលប៉ុន្មានថ្ងៃដែរដើរបោសសំអាតហ្នឹងពូ?

សែនៈ ប្រហែលល្បាក់មួយអាទិត្យបានចេញមកប្រជាជន ។

វណ្ណៈ បាទ! ចុះពេលដែលដើរបោសសំអាតហ្នឹង តើពូមានឃើញសកម្មភាពទាហាន លន់ នល់ ត្រូវបានទាហានខាងខ្មែរក្រហមអីចាប់ធ្វើបាបអីយ៉ាងម៉េចដែរអត់?

សែនៈ ចូលទៅគ្រាន់តែពីណាធ្វើទាហានហ្នឹង គេទម្លាក់អាវុធ ទម្លាក់អីអស់ហ្នឹង ។

វណ្ណៈ គេឲ្យទម្លាក់អាវុធ?

សែនៈ បាទ! គេឲ្យទម្លាក់អាវុធ ។

វណ្ណៈ ហើយគេចាប់?

សែនៈ មើលទាហានហ្នឹងគេស្លៀកពាក់ខោអាវធម្មតាដូចតែយើងចឹង ដូចយើងរាស្ត្រហ្នឹងមិនដឹងជាអ្នកណា ទាហានអាណាអីទេ ។

វណ្ណៈ កាលដំបូងគេគ្រាន់តែថាឲ្យទម្លាក់អាវុធហើយទៅណា ទៅហ្នឹងសិនទៅ ។

សែនៈ បាទ! ដល់ក្រោយមកទៀតទាហានហ្នឹងក៏វាមកតាមជនបទ មកក៏ឃោសនាថាទាហានខាង លន់ នល់ ហ្នឹងអ្នកធ្វើសក្តិអី ។

វណ្ណៈ	សក្តិប៉ុន្មាន?

សែនៈ	សក្តិប៉ុន្មានក៏ចូលមកធ្វើការវិញម៉ោ ។

វណ្ណៈ	បាទ!

សែនៈ	ដល់ចាញ់នយោបាយហ្នឹងក៏ ខ្លះក៏ត្រឡប់មកវិញ ខ្លះអីមក មានអីគេចង់ធ្វើធំក៏ឆាប់ពេលហ្នឹង ទៅ គេយកមកសម្លាប់ចោល ។

វណ្ណៈ	ម៉េចដឹងថាគេយកមកសម្លាប់?

សែនៈ	ហ្អេ មិនដឹង មើល ។

វណ្ណៈ	ចូលមក គេចាប់?

សែនៈ	ចូលមក គេចាប់ ។ ព្រោះប្រាប់គេ ។

វណ្ណៈ	ចុះពូមានបានឃើញគេយកទៅសម្លាប់ផ្ទាល់ទេ?

សែនៈ	អត់ទេ ។

វណ្ណៈ	ចុះកាលហ្នឹងកងពលអីខ្លះដែរ ដែលវ៉ៃចូលទៅទីក្រុងភ្នំពេញ កងពលប៉ុន្មានទៅ?

សែនៈ	កងពលទី៤, កងពលទី១ ។

វណ្ណៈ	កងពលពូ?

សែនៈ	ខ្ញុំនៅកងពលទី១ ៣១០ ។

វណ្ណៈ	បាទ!

សែនៈ	បាទ!

វណ្ណៈ	ចុះហើយមកទៀតពូនៅយាមនៅកន្លែងណាទៅ?

សែនៈ	ខ្ញុំនៅកងតូច នៅស្ពានជ្រោយចង្វារ បែកកង់ៗអីចឹងទៅណា ខ្ញុំខាងត្រឹមផ្សារថ្មីមកគីឡូលេខ៩

វណ្ណៈ	បាទ!

សែនៈ	ដល់ពួកនិរតី ចាប់ពីផ្សារថ្មីទៅ បែកផ្លូវគ្នា ខាងបូព៌ាក៏បែកដីគ្នា ។

វណ្ណៈ	បាទ! ចុះកាលហ្នឹងពូមានស្គាល់ថ្នាក់ដឹកនាំធំៗទេ ស្គាល់ ប៉ុល ពត អីទេ?

សែនៈ	បានស្គាល់ប្រហែលជា១០នាទី ។

វណ្ណៈ	ចុះពីណាទៀតដែលពូស្គាល់?

សែនៈ	ស្គាល់ វឿន, កុច, ភីម ។

វណ្ណៈ	អូហ៏ ហ្នឹងសុទ្ធតែមេ ដឹកនាំកងពលហ្អី?

សែនៈ	បាទ!

វណ្ណៈ  ចុះកាលហ្នឹងសោ ភឹម អី?

សែនៈ  សោ ភឹម ហ្នឹងគាត់គណៈដឹកនាំភូមិភាគ ។

វណ្ណៈ  បាទ គាត់ចូលដល់ទីក្រុងនៅឆ្នាំណា?

សែនៈ  ចូលដល់ ។

វណ្ណៈ  ចុះក្រោយមកទៀតពូធ្វើអីដែរ កាលឆ្នាំ៧៦, ៧៧អីទៅណា?

សែនៈ  ធ្វើស្រែ ធ្វើភ្លឺ ។

វណ្ណៈ  ម៉េចទៅស្រែ ធ្វើអីវិញ?

សែនៈ  ធ្វើត្រង់បឹងប្រយាបហ្នឹង ។

វណ្ណៈ  បាទ!

សែនៈ  ចប់ថានាំគ្នាទៅមើលសិល្បៈ ដល់មើល គេឲ្យមើលសិល្បៈគីឡូលេខ៦ហ្នឹង ដល់ព្រលឹមឡើង គេឲ្យរកចប រកចបទៅកាប់នៅនឹងឃ្លាំងទៅធ្វើដងធ្វើអី ស្រាប់តែបាន២ថ្ងៃគេឲ្យយកចបទៅកាប់ដេញដី ធ្វើស្រែ ធ្វើផ្ទះ ។

វណ្ណៈ  បាទ!

សែនៈ  ថាអស្ចារ្យហើយខំវៃប៉ុណ្ណឹងហើយឲ្យឯថូទៅធ្វើស្រែ ។

វណ្ណៈ  ចុះពូកាលហ្នឹងពូមានដឹងថាគេចាប់ ចាប់ផ្ដើមចាប់មេដឹកនាំធំៗមេកងពលនៅឆ្នាំណាដែរ?

សែនៈ  កងពលនិរតី?

វណ្ណៈ  ពួកនិរតីមក?

សែនៈ  បាទ!

វណ្ណៈ  ឆ្នាំណាពូ?

សែនៈ  ឆ្នាំ៧៧ ។

វណ្ណៈ  ឆ្នាំ៧៧ បានគេចាប់ផ្ដើមចាប់មេធំៗ?

សែនៈ  បាទ! ចាប់មេហ្នឹងខាង សោ ភឹមហ្នឹង ចង់សើរើណា?

វណ្ណៈ  ចង់សើរើយ៉ាងម៉េច?

សែនៈ  ចង់វៃទីក្រុងភ្នំពេញហ្នឹង ។

វណ្ណៈ  ម៉េចពូដឹងថាខាងសោ ភឹម ហ្នឹងចង់រើ វៃទីក្រុងភ្នំពេញហ្នឹង?

សែនៈ  ព្រោះដេញយុទ្ធជនហ្នឹងមានដឹងអី ដល់ពួកនិរតីគេចាក់ខ្សែអាត់ឲ្យយើងស្ដាប់ថា សោ ភឹម ហ្នឹងចង់សើរើចង់វៃប៉ុល ពត ហ្នឹងបើសិនណា អីចឹងបានឲ្យអាយឿន អាអី អាយឿន

កងពិសេសវាប្រហែល៨,១០, ២០នាក់។ យប់ហ្នឹងវាទៅហើយទៅ ត្រៀមទីស្នាក់ការហ្នឹង ហើយពួកកងពលទាំង៤ហ្នឹងនៅត្រង់គីឡូលេខ៩ហ្នឹង ព័ទ្ធទៅដល់ពេល ព័ទ្ធរួចអស់ហើយទីក្រុងភ្នំពេញ ប៉ុន្តែចេះតែតែមកចាំមើលម៉ោងស្មើណា ភីម ហ្នឹងម៉ោង ស្មើណា ចេះតែតេមក ពួកសេរីហ្នឹងមួយជំនាន់ហ្នឹង ដល់បានផែនការហ្នឹងវាធ្វើមិនកើតអីមិន កើតព្រួដល់ ប៉ុល ពត ហ្នឹង ប៉ុល ពត ចាប់ព្រឹប ដល់ចាប់ព្រឹបទៅ គេថត មិនដឹងគេធ្វើម៉េចទេ បានចេញ បានសារភាពម៉ោគេចង់សេរីអីចឹង។

វណ្ណៈ  បែកការទៅ?

សែនៈ  បែកការ។

វណ្ណៈ  ចុះមេពួត្រូវបានគេចាប់អស់?

សែនៈ  ចាប់អស់។

វណ្ណៈ  គេចាប់នៅឆ្នាំណាទៅ?

សែនៈ  ៧៧ប៉ុន្តមិនដឹងខែណាទេ។

វណ្ណៈ  បាទ! ពេលគេចាប់មេហើយ ចុះកូនចៅដូចជាពូអីគេធ្វើម៉េចដែរ?

សែនៈ  ដូចខ្ញុំអីគេជម្លៀសពីភ្នំពេញមកឲ្យទៅនៅខាងកំពង់ចាម ជម្លៀសខ្ទេចហ្នុង។

វណ្ណៈ  បាទ! ចុះពូអីបានធ្វើអីតិចតួចដែរហីអត់ទេ?

សែនៈ  កាលហ្នឹងខ្ញុំបានធ្វើប្រធាន។

វណ្ណៈ  ប្រធានថ្នាក់អីដែរ ហើយឆ្នាំណា?

សែនៈ  ខ្ញុំប្រធាន។

វណ្ណៈ  ប្រធានអីគេដែរពូ?

សែនៈ  ប្រធាននយោបាយវរសេនាតូច។

វណ្ណៈ  វរសេនាតូច?

សែនៈ  បាទ!

វណ្ណៈ  ពូធ្វើប្រធាននយោបាយវរសេនាតូចបានប៉ុន្មានឆ្នាំដែរ?

សែនៈ  បានកន្លះឆ្នាំ តែទៅដល់ប៉ុល ពត ហ្នឹង គេទម្លាក់ខ្ញុំចោល។ គេថាឲ្យតែមេៗគេសម្លាប់ចោល ដល់នេះទៅខំប្រឹងនោះប្រឹង គេប្រើធ្វើអីក៏ដោយប្រឹងមិនហ៊ានទម្រន់តាមគេទេ ដល់នេះ ចេះតែប្រឹងៗកសាងឡើងបានប្រធានក្រុមឡើងវិញឲ្យគេមើល ជំនាន់ហ្នឹងពួកនិរតីគេមកមើល

មកក្តាប់ឡើងដល់កងតូច ដល់យូរមែនទែន បានខ្ញុំឡើងដល់កន្លែងចាស់ខ្ញុំវិញ ឡើងដល់វរសេនាតូច ។

វណ្ណៈ អូហ៏! ចុះពូចេញទៅកំពង់ឆ្នាំងហ្នឹងនៅឆ្នាំណា?

សែនៈ ទៅធ្វើព្រលាននៅកំពង់ឆ្នាំងហ្នឹងហ្អី?

វណ្ណៈ បាទ!

សែនៈ គេឲ្យទៅធ្វើអាហាននៅកំពង់ឆ្នាំង ក្មេច ។

វណ្ណៈ ដោយសារតែពូថាគេចាប់មេនៅឆ្នាំ៧៧ហើយ?

សែនៈ បាទ៧៧ ។

វណ្ណៈ ចឹងប្រហែលចាប់មេហើយហ្នឹងទៅ?

សែនៈ បាទ! ចាប់មេហើយហ្នឹងទៅហ្មង ។ ប្រហែលជា៧៧ហើយប៉ុន្តែវាមិនទាន់ដាច់ហ្អា ។

វណ្ណៈ បាទ! អីចឹងពូទៅគេឲ្យពូធ្វើអីខ្លះទៅ?

សែនៈ ខាងសំណង់ គេឲ្យធ្វើផ្ទះថ្មប្រាំជាន់ ។

វណ្ណៈ បាទ!

សែនៈ ធ្វើផ្ទះថ្មប្រាំជាន់ ធ្វើៗឡើងដល់លើហើយផ្ទះថ្មប្រាំជាន់ បានយួនវៃចូលមកហ្នឹង ។

វណ្ណៈ បាទ! ឥឡូវហ្នឹងផ្ទះថ្មនៅដល់រាល់ថ្ងៃ?

សែនៈ បាទ! នៅសព្វថ្ងៃហ្នឹង ។ កាលខ្ញុំធ្វើហ្នឹងរៀបនឹងដាក់កញ្ចក់ហើយដំបូលលើប៉ុន្តែមិនទាន់ដាត់ទេ ។

វណ្ណៈ គ្រាន់តែសាងសង់ឡើង?

សែនៈ បាទ! គ្រាន់តែសាងសង់ឡើង ។

វណ្ណៈ បាទ! កាលដែលសាងសង់នៅព្រលានហ្នឹងមានយុទ្ធជនច្រើនទេពូ?

សែនៈ បាទ! ច្រើន ។

វណ្ណៈ ប្រហែលជាប៉ុន្មានរយនាក់?

សែនៈ អូហ៏ ប៉ុន្មានកងពលណោះ មួយខាងភូមិភាគយើងទៅទាំងអស់ សុទ្ធតែទ័ពទាំងអស់ ទ័ពទាំងស្រី ទាំងប្រុស ។

វណ្ណៈ ចុះជំនាញការអ្នកម៉ៅសំណង់ ម៉ៅអើ អ្នកម៉ៅធ្វើមើលការខុសត្រូវខ្មែរយើង ឬក៏មានជនជាតិដែរ?

សែនៈ ចិន សុទ្ធតែចិន ។

វណ្ណៈ  ហេតុអីបានពូដឹងថាជាចិន ជនជាតិចិន?

សែនៈ  ចិនមកបង្ហាត់ខាងបច្ចេកទេស ។

វណ្ណៈ  បង្ហាត់ពូផ្ទាល់ហ្នឹងហ្អី?

សែនៈ  បាទ!

វណ្ណៈ  ចិនមកគ្នាច្រើនទេពូ?

សែនៈ  ច្រើនដែរ ប្រហែល២០០, ៣០០នាក់ ។

វណ្ណៈ  អូហ៏ ចិន?

សែនៈ  ប៉ុនមុខជំនាញច្រើន ។ ធ្វើខាងព្រលាននោះផ្សេង មិនមែនធ្វើខាងព្រលាននោះផ្សេងទៅ ខាងផ្ទះថ្មផ្សេងទៅ ខាងហ្គារាសឡាន មុខជំនាញទាំងអស់ហ្នឹង ។

វណ្ណៈ  បាទ! អីចឹងប្រហែលខ្ទង់៣០០នាក់ណោះ?

សែនៈ  បាទ! ប្រហែល២០០, ៣០០នាក់ ។

វណ្ណៈ  អូហ៏! អីចឹងនៅច្រើនដែរ?

សែនៈ  បាទ!

វណ្ណៈ  អីចឹងពូកាលពូធ្វើហ្នឹងអ៊ឺ...មានការលំបាកខ្លាំងទេ?

សែនៈ  បាទ! ជួបការលំបាកខ្លាំងណាស់ ។ ការលត់ដំដីនាទ់ហ្នឹង ដូចថាដើមឈើចិនដើមអំពិល ដើមឫស្សីហ្នឹងគាស់ឲ្យអស់ឫសតិចមិនឲ្យសល់ទេ មិនឲ្យសល់ហើយយកដីមកលប់ ដល់យកដីមកលប់ហើយលប់ហើយយកមកបុក បុកហើយយកមកថ្លឹង រួចហើយឡានចេះតែដឹកយកមកចាក់ដី ទម្រាំតែបានព្រលានហ្នឹង១ ព្រលានហ្នឹងព្រលានចុះតែកប៉ាល់លឿនៗទៀតណា ។

វណ្ណៈ  ចុះពូកាលហ្នឹងការហូបចុកហ្នឹងគ្រប់គ្រាន់ដែរអត់?

សែនៈ  អ៊ឺ...គ្រប់គ្រាន់តែមេៗ ហើយនិងកូនចៅមិនគ្រប់ ។

វណ្ណៈ  ចុះពូមានដឹងថាពេលហូបចុកអត់គ្រប់គ្រាន់ តើពួកចិនហ្នឹងគេដឹងទេ គេដឹងថាពូហូបអត់គ្រប់?

សែនៈ  អត់ទេ ។

វណ្ណៈ  ហេតុអីបានគេអត់ដឹង?

សែនៈ  គេនៅតែកន្លែងគេ គេរួចទៅ គេមានឡានបើកទៅកន្លែងគេផ្សេងទៀតឆ្ងាយពីកន្លែងយើង ។

វណ្ណៈ  អត់មានអ្នកបកប្រែណាបកឲ្យចិនដឹងទេ?

សែនៈ  អត់ អត់ទេ បែបមិនហ៊ានមើលទៅខ្លាច ។

វណ្ណៈ ចុះពូនៅហ្នឹងដែលឃើញគេចាប់យុទ្ធជនយុទ្ធអីទៅណាទេ យុទ្ធជនដែលធ្វើទាហានហ្នឹងមានគេចាប់យកទៅណាទេ?

សែនៈ គេចាប់ដឹកអ្នកមេៗ ហ៊ី ដឹកយកមកទីក្រុងភ្នំពេញ ។

វណ្ណៈ ដឹកច្រើនគ្នាទេពូ?

សែនៈ ដឹកច្រើន ។

វណ្ណៈ អីចឹងមានអ្នកស្លាប់នៅកន្លែងព្រលានយន្តហោះកំពង់ឆ្នាំង គេសម្លាប់អីមាននៅហ្នឹងទេ?

សែនៈ មិនសូវទេ ។

វណ្ណៈ មិនសូវ មានតិចហ្អី?

សែនៈ មានតិច ។

វណ្ណៈ មានតិចតួចហ្នឹង ពួកហ្នឹងខុសអីទៅ?

សែនៈ ខុសហ្នឹង ខុសមិនមែនសេ អ៊ុី អាទេ ដល់ធ្វើការយូរទៅទន់ដៃទន់ជើង ដល់ទន់ដៃទន់ជើងខ្ជិលធ្វើការធ្វើអី ដល់យូរៗគេចាប់បានយកទៅវៃចោល គ្មានអាណាបង្ខំធ្វើអីគ្នាទេ ។

វណ្ណៈ ចុះអ្នកដែលធ្វើការមើលការខុសត្រូវខ្មែរយើងណា ឈ្មោះអីខ្លះទៅពូ អ្នកមេការមើហការខុសត្រូវពូអីនៅកន្លែងហ្នឹងណា?

សែនៈ ភ្លេច ភ្លេចអស់ហើយវាយូរទៅហើយ ។

វណ្ណៈ បាទ!

ដានីៈ ចុះពូគេចាប់ ជំនាន់គេចាប់ហ្នឹង គេចាប់ទៅពីថ្នាក់ណាដល់ថ្នាក់ ណាទៅ?

សែនៈ គេចាប់ហ្នឹង គេចាប់ឲ្យតែគេប្រទាក់បានគេឆ្លើយដាក់មកគេចាប់ទាំងអស់ ដូចថាគេចាប់វរសេនាតូចអីចឹង វរសេនាតូចឆ្លើយ ឆ្លើយទៅតាមខ្សែអីចឹងទៅ ។

វណ្ណៈ ចុះកាលជំនាន់កាលវរកងពលមានចាប់ទេ?

សែនៈ មានចាប់ ។ ចាប់រហូតដល់វរកងពល វរសេនាតូច ។

វណ្ណៈ ចុះពូឋានៈវរសេនាតូចដែរម៉េចមិនចាប់?

សែនៈ អ្ហេ អីចឹងបានខ្ញុំឆ្ងល់ ។ ប្រធាននយោបាយទៀតណា ។

វណ្ណៈ ចុះពូធ្វើដល់ព្រលានយន្តហោះពូធ្វើដល់ឆ្នាំណា?

សែនៈ ធ្វើបានមួយឆ្នាំ ។

វណ្ណៈ ហើយពូមកណាវិញត្រឡប់មកណាវិញ?

សែនៈ ដល់ធ្វើ មិនទាន់រួចផង កាលណោះគេវៃរួមមក គេវៃៗកាលដែលគេប្រយុទ្ធណោះ យួនវៃចូលហើយ វៃចូលហើយ ដល់រទេះចិននាំគ្នាអូស អូសអង្ករទៅតាមអមលាំង ចាក់ចេះទៅនៅអមលាំងៗ កាំភ្លើងគ្រិលៗរួចមិនជឿថាយួនចូលមកបានទៀតណា ។ ទៅតាមអមលាំងស្រាប់ទៅបានតែមួយខែ ពួកបូព៌ាមកៗដល់នេះគេ កងពលគេឲ្យចាប់ ពួកបូព៌ាហ្នឹងណា ។ ចាប់ពួកបូព៌ាគេបញ្ជូនទ័ពមក ទ័ពបូព៌ាមកទាំងអស់ទាំងក្មេង ទាំងចាស់ ទ័ព ។

វណ្ណៈ ឆ្នាំជិតបែកហ្នឹងហ្អីពូ?

សែនៈ បាទ! ជិតបែកហ្នឹង ។

វណ្ណៈ ចាប់យកទៅណាពួកហ្នឹង?

សែនៈ គេចាប់យកទៅសម្លាប់ចោលនៅក្នុងព្រៃ អមលាំងនោះ ។

វណ្ណៈ អូ! ច្រើនទេពូ?

សែនៈ បាទ! អូ! វៃច្រើនណាស់ រួចវៃហ្នឹងប្រាប់ពួកបូព៌ាថា បូព៌ាឥលូវទៅចូលទ័ពនេះ៩០១ អីចឹងទៅ៣១០អីទៅ ចូលទៅ ឥឡូវយើងបំបែកទៅខាងហ្នុងគេថាឃាត់ៗទៅ ឥឡូវយើងបំបែកមកនៅខាងកន្លែងភូមិភាគគេវិញ រួចគេនោះគេនិយាយគ្នារួចស្រេចហើយ ថាឥឡូវ ២នាក់ធ្វើម៉េចឲ្យបានម្នាក់ឥឡូវពួកបូព៌ាមកបាន១០០នាក់ហើយពួកបូព៌ាមក ១០០នាក់ដល់នេះមេគេថា ឥឡូវតម្រង់ជួរទៅ តម្រង់ជួរទៅគេឲ្យពួកបូព៌ាហ្នឹងឈរមុខយើង ហ្នឹងឈរមុខយើងម្នាក់ដល់គ្នាយើងនៅក្រោយនេះ គ្នាយើង២នាក់គេម្នាក់ ធ្វើម៉េចចាប់ឲ្យ បានបើរួចទទួលខុសត្រូវ រួចអ្នកដែលជីប្រឡាយជីកទៅ ប្រឡាយដូចស្ទឹង ។

វណ្ណៈ ជីកធ្វើអីពូប្រឡាយហ្នឹង?

សែនៈ ជីកវៃចោលហ្នឹង ។

វណ្ណៈ អ៊ូ!

សែនៈ គ្រាន់តែកញ្ចែច្រេកគ្រាន់តែរៀបហ៊ុំទុកសាកាដូរហ្នឹងហើយ គ្រាន់តែមកនៅនឹងកងគេ គ្រាន់តែកញ្ចែច្រេកអ៊ុកៗផ្ទាប់ហ្នុង ទិបជាប់គេរុញទៅយកទៅព្រៃអមលាំងព្រៃច្រើន ស្រាប់តែរុញវៃដាក់ផុងៗត្រឡប់មកអង្គុយវិញ ។

វណ្ណៈ បាញ់ឬក៏វៃ?

សែនៈ វៃ ។ យកដំបងអីលាក់ក្នុងស្មៅ ។ មួយសន្ទុះគេបញ្ជូន មិនដឹងជាបញ្ជូនពីណាមកទេ យកដល់ហ្នឹងទៀតហើយ មកដល់កញ្ចែច្រេក មួយថ្ងៃហ្នឹងវៃហ្នឹងវៃរាប់ពាន់នាក់ ទាហានខាងបូព៌ាហ្នឹង ។

វណ្ណៈ    ទាហានហ្នឹងទាហានមកពីណាមក?

សែនៈ    ទាហានបូព៌ាហ្នឹង បែបគេជម្លៀសពីហ្នឹងមកមើលទៅ ។

វណ្ណៈ    គតីរមកដល់អមលាំងហ្នឹងវ៉ៃទាហានខាងនិរតីហ្នឹកងទ័ពនៅព្រលានហ្នឹងចាប់ទៅ?

សែនៈ    បាទ! ចាប់ ។

វណ្ណៈ    គេប្រជុំឲ្យចាប់?

ដានីៈ    អ្នកណាជាអ្នកបញ្ជាឲ្យចាប់ពូមានដឹងទេ?

សែនៈ    អត់ អត់ដឹងទេ ។ អត់ស្គាល់ផង ដល់វាបាក់បែកគ្នាអស់ទៅ ។

វណ្ណៈ    អីចឹងស្លាប់អស់ច្រើន?

សែនៈ    អូ! ស្លាប់អស់ហ្មង ទ័ពៗស្លាប់នៅសល់៣០នាក់ ៣០នាក់ហ្នឹង មុនដំបូងវ៉ៃៗទៅ វារត់ទៅពួកទាហានរាយខ្សែត្រៀមរត់ៗទៅរួចប្រហែល៣០-៤០នាក់ រត់ទៅនៅភ្នំឱរ៉ាល់នេះ មកនៅភ្នំឱរ៉ាល់នេះ ហើយដល់ទ័ពមកដល់ឃើញនៅហ្នឹងក៏យកមកទៀតមក យកមកវ៉ៃទៀត វាអត់ហ៊ានឆ្លងទៅថៃទៅអីដល់ភ្នំឱរ៉ាល់ហើយហ្នឹងណា ដល់៣០នាក់ ហ្នឹងបង្ហើយហ្មងអស់រលីងទ័ពបូព៌ា ។

វណ្ណៈ    អូហ៏! អីចឹងទ័ពខាងព្រលានមានគ្នាច្រើនហ្អី?

សែនៈ    មានគ្នាច្រើន ។

វណ្ណៈ    តែក្រោយមកមានគេចាប់ខ្លះទេ?

សែនៈ    ក្រោយមកចាប់ផ្ដើមវ៉ៃហើយនែ៎ វ៉ៃជាមួយយួន ហ្នឹងលែងសម្លាប់ហើយ ចាប់ផ្ដើមវ៉ៃជាមួយយួន ដល់វ៉ៃចុះឡើងចុះឡើងទៅខ្ញុំដូចអត់មានបានផលប្រយោជន៍អីទេ រៀបខ្សែត្រៀមទៅយួនដេញៗ គ្មានបានអីទេ ខ្ញុំយហ៏ទ័ពទៅរៀបចោលនៅភ្នំឱរ៉ាល់ រៀបចោលទៅខ្ញុំនាំនិរសាខ្ញុំ៣នាក់៦នាក់រត់ម៉ោ ។

វណ្ណៈ    អីចឹងពូមាននិរសាដែរ?

សែនៈ    បាទ! រត់មកហ្មងខ្ញុំរត់មក រត់មកខាងសន្ទុកនេះវិញ ។

វណ្ណៈ    ចុះនិរសាពូឈ្មោះអីខ្លះទៅ?

សែនៈ    ឈ្មោះ ភាព ឈ្មោះអីទេ ភ្លេចឈ្មោះហើយក្មេងៗអ្ហី ។

វណ្ណៈ    ហើយសព្វថ្ងៃពូមានដឹងថានៅទេ នៅណា?

សែនៈ    នៅ ។

វណ្ណៈ    អត់ដែលបានទាក់ទងគ្នាទេ?

សែនៈ អត់ដែលបានទាក់ទងគ្នាទេ ។

វណ្ណៈ អ៊ីចឹងពូខ្ញុំចង់សួរត្រឡប់ក្រោយតិច ពេលដែលពូថាចិនរាប់រយនាក់ហ្នឹង តើពួកហ្នឹងដឹងថាសភាពការណ៍ចេញទៅមុន ឬក៏នៅហ្នឹង?

សែនៈ ចេញទៅមុន ។

វណ្ណៈ ចេញទៅប្រហែលជាប៉ុន្មាន?

សែនៈ ចេញប្រហែលជា២ម៉ោង ។ ចេញប្រហែលជា២ម៉ោងបានទ័ពយើងចេញទៅអមលាំងរួចចេញហ្នឹងចេញទៅៗលិចទេ ទៅបាត់ដំបងទេ ។

វណ្ណៈ ចិនហ្នឹង?

សែនៈ បាទ!

វណ្ណៈ ជិះអីទៅ?

សែនៈ ជិះអាប៉ឺសយើងហ្នឹង ។

វណ្ណៈ អូហ៏! អ៊ីចឹងអត់ជិះយន្តហោះទេចឹង?

សែនៈ បាទ!

វណ្ណៈ ចឹងប្រហែលជាចេញដំណើរថ្មើរជើងចូលថៃចូលអី?

សែនៈ ចូលថៃមើលទៅ ព្រោះអ្នកជម្លៀសគេឲ្យចេញទៅអ៊ីចឹងទៅបាត់ដំបង ។

វណ្ណៈ អ៊ីចឹងពេលដែលជិតបែកហ្នឹងចិនក៏នៅហ្នឹងដែរ?

សែនៈ ចិនក៏នៅហ្នឹងដែរ ។

វណ្ណៈ ចុះពូមានដឹងថាចិនទៅដល់ណាៗពូមានដឹងទេ?

សែនៈ អត់ដឹងទេ ។ អត់មានដឹងដំណឹងថាទៅដល់ណាៗ

វណ្ណៈ ចុះពេលដែលបែកវៀតណាម វ៉ៃដល់អមលាំងហើយពូទៅណាទៀត?

សែនៈ អាហ្នឹងគេ គេឲ្យទៅភ្នំឱរ៉ាល់ គេឲ្យចែកកាំភ្លើងហ្មង ប៉ុនកាំភ្លើងទៅឲ្យយកចេញពីឃ្លាំងបានសុទ្ធតែសេកាទេ អត់បានកាំភ្លើងអាការ កាំភ្លើងអីទេ ដល់ក្រោយមកបានមានកាំភ្លើងល្អៗឲ្យ ។

វណ្ណៈ ចុះពូអ៊ឺ...ពូរត់ដល់ឆ្នាំណាបានពូត្រលប់មកចូលភូមិវិញ?

សែនៈ រត់ដល់ឆ្នាំ៧៩ ។

វណ្ណៈ ពូរត់ដល់ណាខ្លះ?

សែនៈ រត់ដល់ភ្នំឱរ៉ាល់ត្រឡប់មកវិញ ។

វណ្ណៈ	ឆ្នាំណាពូត្រឡប់វិញ?

សែនៈ	ឆ្នាំ៧៩ ។

វណ្ណៈ	ឆ្នាំ៧៩ហ្នឹងដែរ?

សែនៈ	បាទ!

វណ្ណៈ	ចុះរឿងរ៉ាវដែលពូធ្លាប់ឆ្លងកាត់ពូមានដែលនិយាយប្រាប់កូនចៅបងប្អូនឲ្យបានដឹង ទេ?

សែនៈ	បានប្រាប់ដែរ ។

វណ្ណៈ	ប្រាប់ទៅក្មេងៗជឿដែរ?

សែនៈ	វាអត់ជឿវាថាវាមិនដែលទ័ពណាពិបាកវេទនាស៊ីបបរ ក្បាលជន្លង់ណា ក្អៅតូចជាងក្បាលជន្លង់វាអត់ជឿអីចឹងយើងទេ រួចខាងមុខនោះគេចង់មកនៅក្រោយ ក្រោយនោះគេចង់ទៅមុខ ក្រោយថានេះស្រួល កាលជំនាន់ហ្នឹងហ្ន៎ ។

វណ្ណៈ	ចុះពូគិតថាកាលរបបខ្មែរក្រហមជារបបមានលក្ខណៈយ៉ាងម៉េច?

សែនៈ	វាលំបាកវេទនាណាស់របបខ្មែរក្រហម ស៊ីតែបបរ កាប់សម្លាប់មនុស្សគ្មានត្រាប្រណី របបនេះឃោរឃៅមែនទែនហ្មង គ្មានគុកគ្មានអីដាក់ទេ ហើយបើមនុស្សនេះហ្នឹងដាក់ខ្នោះចេះខ្នោះដាក់អានុកមួយហ្នឹងហ្អា ឲ្យដេកនឹងស្នូកជ្រូកមានឃើញទេ ស្នូកជ្រូកអីចឹងហ្មែ ឲ្យដេកពីលើ ។

វណ្ណៈ	ពូធ្លាប់ឃើញទេ?

សែនៈ	បាទ! ធ្លាប់ឃើញ ។

វណ្ណៈ	គុកនៅកន្លែងណាទៅ?

សែនៈ	គុកនៅកន្លែងអន្លុភាព ។

វណ្ណៈ	អីចឹងនៅអន្លុភាពមានគុកដែរ?

សែនៈ	បាទ!

ដានីៈ	ចុះពូកាលពូគេមិនទាន់ចាប់មេធំៗពូមានឋានៈជាវរៈអីចឹង ពូធ្លាប់បានចូលប្រជុំជាមួយដូចថាខាងមកពីអគ្គសេនាធិការ?

សែនៈ	មិនសូវទេ ។

វណ្ណៈ	ពូស្គាល់ដែរអត់អគ្គសេនាធិការ?

សែនៈ	ស្គាល់តាភូមិភាគ ភូមិភាគហ្នឹងឈ្មោះ ភីម ហ្នឹង ។ កាលគេហៅទៅប្រជុំនៅស្ពាតអូរឡាំពិកហ្អា ។

វណ្ណៈ  បាទ!

សែនៈ  ទៅដល់គេថា ទៅពីម៉ោង២គេថា ចាំស្តាប់គណៈបក្សគេ ចូលដល់ ភឹម ហ្នឹងមេគេធំៗគេឈរលើវេទិកា ប៉ុល ពត ហ្នឹង គេអង្គុយហ្អា គេឈរចំកណ្តាល ខ្ញុំទម្រាំចូលដល់ព្រលប់ ដល់ហើយចាំស្តាប់គេនិយាយរឿងប្រវត្តិគេ ប្រវត្តិគេតស៊ូ ។ ទម្រាំតែជួបជុំគ្នា៣ខែទម្រាំគាជួបជុំគ្នាម្តងៗហ្អា បាទ គេនិយាយប្រវត្តិគេហ្អា ។

វណ្ណៈ  បាទ! ពីណាអ្នកនិយាយ?

សែនៈ  ប៉ុល ពត ។ គ្រាន់តែឃើញម៉ាភ្លែតទេ មាឌអីចឹងហ្នេ សអីចឹង គ្រាន់គាឃើញម៉ាភ្លែតគាត់ខ្ញុំមានរវល់ណាស់ខ្ញុំអត់បាននៅប្រជុំទេ ចាំចាក់ខ្សែអាត់ខ្ញុំទៅចាំស្តាប់ទៅ ស្រាប់គានេះគេចេញប្រុចបាត់ឯថ្ងនេះអង្គុយចាំស្តាប់ខ្សែអាត់ ម៉ែហើយម៉ាយប់ ។

វណ្ណៈ  ឆ្នាំណាទៅលោកពូ?

សែនៈ  ឆ្នាំ៧៩ហ្នឹងណា ។

វណ្ណៈ  ចុះក្រៅពី ប៉ុល ពត មានពីណាទៀតទៅលោកពូ?

សែនៈ  អត់មានទេ មានតែគាមកងពល កងពលប្រជុំវរសេនាតូចទេ វរសេនាតូចប្រជុំកងតូចអីហ្នឹង ។

វណ្ណៈ  ពូអត់ស្គាល់ សិន សេន ទេអីចឹង?

សែនៈ  គ្រាន់តែឮគាឈ្មោះ ។

វណ្ណៈ  គាត់ធ្វើអី?

សែនៈ  សិន សេន ហ្នឹង ខាងៗភូមិភាគដែរ ។

វណ្ណៈ  ចុះ នួន ជា អីពូស្គាល់ទេ អៀង សារី អី?

សែនៈ  អត់ទេមិនឃើញឈ្មោះទេ។ បើនេះ បើអី ហូ នឹម ។ នៅក្បែរកន្លែងខ្ញុំនៅ ហូ នឹម ។

វណ្ណៈ  ពូស្គាល់គាត់ច្បាស់ទេ?

សែនៈ  បាទ! ហែមិនស្គាល់ គាត់ប្រជ្រុយ ។

វណ្ណៈ  គាត់នៅខាងអី?

សែនៈ  គាត់នៅខាងក្រសួងឃោសនាការ ក្រសួងឃោសនាគាត់ឡើងចុះៗបានម៉ានថ្ងៃ ស្រាប់តែគេយកទៅវៃចោលបាត់ទៅហើយ ។

វណ្ណៈ  បាទ! ពូមានដឹងគេចាប់គាត់ទេ?

សែនៈ  គ្រាន់តែឮគេថា គេគ្រាន់គាថាគេចាប់ៗ ស្រាប់តែបាត់ហ្មង ។

វណ្ណៈ	អូ! ចុះពូរដ្ឋាភិបាលយើង បានចុះហត្ថលេខាជាមួយអង្គការសហប្រជាជាតិស្ដីពី តុលាការ ដើម្បីបង្កើតតុលាការសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម តើពូយល់ថាការ បង្កើត តុលាការសម្រាប់កាត់ទោសហ្នឹងវាជាការត្រឹមត្រូវទេ?

សែនៈ	បាទ! ត្រឹមត្រូវហើយ ។

វណ្ណៈ	ហេតុអីបានពូថាត្រឹមត្រូវ?

សែនៈ	ព្រោះអ្នកដឹកនាំហ្នឹងវាឃោរឃៅណាស់សមតែកាត់ទោសសម្លាប់ចោល ពួកខ្មែរក្រហមអ្នក ដឹកនាំធំៗ អីចឹងពូចិត្តពូចង់ឲ្យមានការកាត់ទោសដែរ?

វណ្ណៈ	អីចឹងពូ ចិត្តពូចង់ឲ្យមានការកាត់ទោសដែរ?

សែនៈ	បាទ ចង់ឲ្យមានការកាត់ទោស ព្រោះលំបាកវេទនាណាស់កាលជំនាន់ហ្នឹង ។

វណ្ណៈ	បាទ! ចុះពូមានអ្វីចង់បន្ថែមទៀតទេ នូវអ្វីដែលខ្ញុំអត់បានសួរពូទេ?

សែនៈ	មានស្អីទៀតទេ អស់ហើយអ្ហឺ...។

វណ្ណៈ	អីចឹងខ្ញុំអរគុណពូច្រើនហើយដែលពូបានផ្ដល់បទសម្ភាសន៍ឲ្យខាងពួកខ្ញុំពូ ។

សែនៈ	បាទ

វណ្ណៈ	អីចឹងពូមានសល់រូបថតអីទេ ពូ?

ចប់